ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# សារអបអរសាទរ

## ក្នុងឱកាសនៃការបើកការដ្ឋានសាងសង់ «ព្រែកជីកហ្វូណនតេជោ»

តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីនគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) យើងខ្ញុំទាំងអស់គ្នាសូមចូលរួមសម្ដែងអំណរសាទរ ប្រកប ដោយមនោសញ្ចេតនារំភើបរីករាយយ៉ាងក្រៃលែងជាមួយបងប្អូនជនរួមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា និងនៅលើសកលលោក ក្នុងឱកាសនៃការបើកការដ្ឋានសាងសង់ «ព្រែកជីកហ្វូណនតេជោ» នាថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២៤។

ក្នុងឱកាសមហាដ៏នក្ខត្តឫក្សនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណាខ្ញុំ សូមសម្ដែងនូវការគាំទ្រយ៉ាងភ្លៀវភ្លាចំពោះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតប្រមុខរាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្ដួចផ្ដើម និងសម្រេចចិត្តដ៏ត្រឹមត្រូវ ប្រកបដោយគតិបណ្ឌិត និងទស្សនវិស័យវែងឆ្ងាយក្នុងការកសាង «ព្រែកជីកហ្វូណនតេជោ» ដើម្បីបម្រើដល់ឧត្តមប្រយោជន៍ជាយុទ្ធសាស្ត្ររបស់ជាតិ និងប្រជាជនកម្ពុជា ។

ក្រោយស្ថាបនារួចរាល់ «ព្រែកជីកហ្វូណនតេជោ» នឹងដើរតួនាទីយ៉ាងសំខាន់រួមចំណែកជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម តាមរយៈពហុមុខងារដ៏មានសក្ដានុពល និងសម្បុរបែបដែលនឹងក្លាយជា៖ បណ្ដាញតភ្ជាប់ឡូជីស្ទីក និងប្រព័ន្ធដឹកជញ្ជូនតាមផ្លូវទឹកកាន់តែមានភាពងាយស្រួលឆាប់រហ័ស និងជាប្រព័ន្ធធារាសាស្ត្រដ៏ទូលំទូលាយបម្រើឱ្យការស្រោចស្រព និងការបង្កើនផលិតភាពក្នុងវិស័យកសិកម្ម, បណ្ដាញចែករំលែកចរន្តទឹកដើម្បីកាត់បន្ថយផលប៉ះពាល់ពីគ្រោះរាំងស្ងួត និងទឹកជំនន់, ជំរុញការវិនិយោគវិស័យទេសចរណ៍តាមផ្លូវទឹក, ការអភិវឌ្ឍដល់វិស័យពាក់ព័ន្ធសំខាន់ៗដទៃទៀត ដែលរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាពលរដ្ឋនៅតាមតំបន់ដែលព្រែកជីកហូរកាត់, និងការជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរយៈការបង្កើន និងការពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា កាន់តែខ្លាំងក្លាថែមទៀតនៅក្នុងតំបន់ និងសកលលោក ហើយជាពិសេសសមិទ្ធផលកេរ្ដិ៍ដំណែលជាប្រវត្តិសាស្ត្រនេះ នឹងក្លាយជាប្រភពធនធាន និងជាមូលធនមិនចេះរីងស្ងួតសម្រាប់ប្រជាជនកម្ពុជារាប់ជំនាន់តទៅអនាគត។

សូមឧទ្ទិសទិវានៃពិធីបើកការដ្ឋានសាងសង់ «ព្រែកជីកហ្វូណនតេជោ» នាឱកាសដ៏វិសេសវិសាលនេះ ថ្វាយព្រះមហាវីរក្សត្រ **ព្រះបរមរតនកោដ្ឋ** និងអតីតអង្គព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់ ដែលព្រះអង្គ បានបូជាព្រះកាយពល និងព្រះបញ្ញាញាណ ព្រមទាំងធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បី បុព្វហេតុថែរក្សា និងការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិ រហូតមកដល់បច្ចុប្បន្ននេះ ។ ទូលព្រះបង្គំខ្ញុំព្រះករុណាខ្ញុំ ក៏សូមព្រះបរមរាជា នុញ្ញាតធ្វើអភិវន្ទនកិច្ច ប្រកបដោយកតញ្ញូតាធម៌ដ៏ស្មោះស្ម័គ្រចំពោះព្រះរាជគុណូបការៈ និងព្រះមហាករុណាធិគុណដ៏ថ្លៃថ្លារបស់ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលជានិច្ចកាលព្រះអង្គ តែងយកព្រះទ័យទុកដាក់ខ្ពស់ និងគង់ប្រថាប់ជាព្រះប្រមុខរដ្ឋនៃឯកភាព និងនិរន្តរភាពជាតិសម្រាប់ព្រះរាជាណាចក្រកម្ពុជាញុំាងឱ្យប្រជារាស្ត្រខ្មែរបានរស់នៅដោយសុខដុមក្រោមព្រះបារមីដ៏ពិសិដ្ឋនៃព្រះបរមរាជសម្បត្តិរបស់ព្រះអង្គ។

ជាថ្មីម្តងទៀត សូមយកឱកាសដ៏ឧត្តុង្គឧត្តមនេះ សម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះមគ្គុទេសន៍ដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានដាក់ចេញគោលនយោបាយ និងផែនការជាយុទ្ធសាស្ត្រយូរអង្វែង ដោយទទួលបាននូវការសាទរយ៉ាងមហោឡារិកពីប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុងសង្គម ដែលបានបង្ហាញពីស្មារតីសាមគ្គីជាតិ និងការរួបរួមគ្នាជាធ្លុងមួយដ៏រឹងមាំ ក្នុងករណីយកិច្ចការពារ ថែរក្សា និងអភិវឌ្ឍប្រទេសជាតិ ឱ្យឈរស្មើមុខស្មើមាត់លើឆាកអន្តរជាតិតាមរយៈការស្ថាបនា «ព្រែកជីកហ្វូណនតេជោ» នេះ។ ទន្ទឹមនេះ ក្រោមការដឹកនាំដ៏ស្វាហាប់នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** យើងខ្ញុំសូមថ្លែងនូវការគោរពកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះ កិច្ចខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ក្នុងការជំរុញចាប់ផ្តើមដំណើរការសាងសង់ «ព្រែកជីកហ្វូណន តេជោ» តាមពេលវេលាដែលបានគ្រោងទុក ដើម្បីឈានទៅសម្រេចបានសមិទ្ធផលជាតិដ៏អច្ឆរិយៈនេះ តាមផែនការកំណត់ ។

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីនគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ជឿជាក់យ៉ាងមុតមាំថា សមិទ្ធផលដ៏គួរឱ្យស្ញប់ស្ញែងប្រកបដោយមោទនភាពនេះ នឹងរួមចំណែកកាន់តែខ្លាំងក្លាថែមទៀត ដល់ការលើកកម្ពស់កិត្យានុភាព និងការបង្កើនកាលានុវត្តភាពសម្រាប់ព្រះរាជាណាចក្រកម្ពុជា ទាំងលើទិដ្ឋភាពនយោបាយ សន្តិសុខ និងសេដ្ឋកិច្ច ជាពិសេសដើរតួនាទីជាកម្លាំងចលករដ៏សកម្ម បម្រើដល់ឧត្តមប្រយោជន៍ជាតិ និងជានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព៕

ថ្ងៃព្រហស្បតិ៍ ១២រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា. ឆ្នាំ២០២៤

ជ.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
អនុប្រធានអចិន្ត្រៃយ៍

ជូ-ប៊ុនអេង